ក្របមុខ

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រមសីលធម៌

## សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២

( ថ្ងៃ អាទិត្យ ទី ១ ខែ មេសា ឆ្នាំ ២០០៧ )

ក្របខ្នង

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត


បោះពុម្ព និង ផ្សព្វផ្សាយ

ដោយ គ.ជ.ប

ក្របបន្ទាប់ពីក្របមុខ

**ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី ២**
**(ថ្ងៃ អាទិត្យ ទី ១ ខែ មេសា ឆ្នាំ ២០០៧)**

# ក្រមសីលធម៌
# សម្រាប់
# អ្នកសង្កេតការណ៍បោះឆ្នោត

បោះពុម្ព និង ផ្សព្វផ្សាយ
ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឆ្នាំ ២០០៦

# មាតិកា

**ទំព័រ**


**អក្សរកាត់** ........ ១

I. **សេចក្តីផ្តើម** ........ ២

II. **ការបកស្រាយ** ........ ៣

III. **គោលដៅ នៃក្រមសីលធម៌** ........ ៤

IV. **តួនាទីនៃអ្នកសង្កេតការណ៍** ........ ៤

V. **សិទ្ធិ ភារកិច្ច និងបម្រាមសម្រាប់អ្នកសង្កេតការណ៍** ........ ៥

**ក. សិទ្ធិ និងភារកិច្ចរបស់អ្នកសង្កេតការណ៍** ........ ៥

**ខ. បម្រាមសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត** ........ ១១

VI. **ទោសប្បញ្ញត្តិ** ........ ១៣

VII. **នីតិវិធីទទួលស្គាល់អ្នកសង្កេតការណ៍** ........ ១៤

**ក. អ្នកសង្កេតការណ៍ជាតិ** ........ ១៤

**ខ. អ្នកសង្កេតការណ៍អន្តរជាតិ** ........ ១៦

VIII. **សំណូមពរ** ........ ១៦

**ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០០៧** ........ ១៨






# អក្សរកាត់

| | |
|---|---|
| ១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | គ.ជ.ប |
| ២. គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត | គខ/កប |
| ៣. លេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត | លខ/កប |
| ៤. គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត | គឃ/សប |
| ៥. គណៈកម្មការការិយាល័យបោះឆ្នោត | គ.ក.ប |
| ៦. គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត | គ.ក.រ |
| ៧. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ត.រ |
| ៨. ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ | ច.ប.ឃ.ស |

## I. សេចក្ដីផ្ដើម

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាដំណើរការមួយ ដែលតម្រូវឱ្យប្រជាពលរដ្ឋទាំងពីរភេទ ដែលមានឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតចុងក្រោយ ដែលបានធ្វើបច្ចុប្បន្នភាពប្រចាំឆ្នាំ និងមានឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនក្នុងពេលបោះឆ្នោតប្រើសិទ្ធិរបស់ខ្លួនក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ។

ដើម្បីធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងត្រូវបានគ្រប់មជ្ឈដ្ឋានទាំងអស់ទទួលស្គាល់អ្នកសង្កេតការណ៍ត្រូវមានជំហរអព្យាក្រឹត មិនលំអៀង មិនប្រកាន់បក្សពួក និងមិនជ្រៀតជ្រែកក្នុងដំណើរការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុម័តក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដើម្បីអនុវត្តក្នុងការសង្កេតមើលដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងព្រះរាជាណាចក្រកម្ពុជា ។





## II. ការបកស្រាយ

១. ពាក្យ " **ការបោះឆ្នោត** " និង " **ដំណើរការបោះឆ្នោត** " មានន័យរួមបញ្ចូលទាំងការចុះឈ្មោះបោះឆ្នោត កុំព្យូទ័រកម្មបញ្ជីបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការចុះបញ្ជីបេក្ខជន ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផលបណ្ដោះអាសន្ន និងបណ្ដឹងតវ៉ា ឬបណ្ដឹងជំទាស់ ឬ/និងបណ្ដឹងទាក់ទងនឹងករណីខាងលើ ។ ប៉ុន្តែពាក្យនេះ ក៏មានន័យរួមបញ្ចូលផងដែរនូវសកម្មភាពនានា មុន និង ក្រោយថ្ងៃបោះឆ្នោតរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងភ្នាក់ងារនៃគណបក្សនយោបាយ ។

២. ពាក្យ " **អ្នកសង្កេតការណ៍** " ក្នុងក្រមសីលធម៌នេះ គឺសំដៅតែលើអ្នកសង្កេតការណ៍ជាតិ និង អន្តរជាតិប៉ុណ្ណោះ មិនបានគិតបញ្ចូលអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ឬភ្នាក់ងារនៃគណបក្សនយោបាយទេ ។

## III. គោលដៅ នៃក្រមសីលធម៌

គោលដៅនៃក្រមសីលធម៌នេះ គឺដើម្បីធានា ៖

១. កិច្ចសង្កេតការណ៍ការបោះឆ្នោត ត្រូវធ្វើឡើងដោយសុចរិត និងតម្លាភាព ។

២. ឱ្យអ្នកសង្កេតការណ៍បំពេញការងារដោយពុំមានការជ្រៀតជ្រែកឡើយ ។

## IV. តួនាទីនៃអ្នកសង្កេតការណ៍

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត ក្នុងដំណើរការបោះឆ្នោតទាំងមូល ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាល បរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិនានាឱ្យចូលរួមសង្កេតការណ៍ការបោះឆ្នោតនៅ ព្រះរាជាណាចក្រកម្ពុជា ។

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានទទួលស្គាល់





អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិធ្វើសកម្មភាពសង្កេតការណ៍ ដោយឯករាជ្យពីរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងទទួលនូវកិច្ចសហប្រតិបត្តិការយ៉ាងពេញទំហឹងពីអាជ្ញាធរដែនដី គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៀតផង ។

អ្នកសង្កេតការណ៍ទាំងឡាយមានសិទ្ធិសង្កេតមើលគ្រប់សកម្មភាពដែលទាក់ទងនឹងការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត ការបូកសរុបលទ្ធផល និងការប្រកាសលទ្ធផលនៃការបោះឆ្នោត ។ ប៉ុន្តែអ្នកសង្កេតការណ៍មិនត្រូវជ្រៀតជ្រែក ឬប៉ុនប៉ងប្រើឥទ្ធិពលរបស់ខ្លួន ក្នុងគោលបំណងរំខាន ឬរារាំងដំណើរការនៃការបោះឆ្នោតឡើយ ។

## V. សិទ្ធិ ភារកិច្ច និងបម្រាមសម្រាប់អ្នកសង្កេតការណ៍

### ក. សិទ្ធិ និងភារកិច្ចរបស់អ្នកសង្កេតការណ៍

នៅពេលបានទទួលស្គាល់ជាផ្លូវការ និងបានទទួលប័ណ្ណសម្គាល់អ្នកសង្កេតការណ៍រួចហើយ អ្នកសង្កេតការណ៍ទាំងឡាយនឹងមានឯករាជភាព ព្រមទាំងមានសិទ្ធិ និងភារកិច្ច ដូចខាងក្រោម ៖

១. អ្នកសង្កេតការណ៍អន្តរជាតិ : អាចធ្វើដំណើរទៅគ្រប់ទីកន្លែងក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ដោយពុំចាំបាច់មានការអនុញ្ញាត ឬជូនដំណឹងជាមុនឡើយ លើកលែងតែដោយសារមូលហេតុច្បាស់លាស់ទាក់ទងនឹងសន្តិសុខផ្ទាល់ខ្លួនប៉ុណ្ណោះ ។

២. អ្នកសង្កេតការណ៍ជាតិ : អាចធ្វើដំណើរសង្កេតការណ៍ក្នុងរង្វង់ខេត្ត ក្រុង ដែលខ្លួនបានស្នើសុំប៉ុណ្ណោះ ។

៣. ក្នុងករណីអ្នកសង្កេតការណ៍មានជួបគ្រោះអាសន្ន ឬអសន្តិសុខអ្វីមួយត្រូវជូនដំណឹងទៅមន្ត្រីបោះឆ្នោតពាក់ព័ន្ធ និងអាជ្ញាធរដែនដី ដើម្បីជួយដោះស្រាយទាន់ពេលវេលា ។

៤. អាចអមដំណើរគណៈប្រតិភូមន្ត្រីបោះឆ្នោត នៃគណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅរាល់ពេលដឹកជញ្ជូនហិបឆ្នោត និងសម្ភារៈបោះឆ្នោតទាំងទៅ និងមក ។





៥. សង្កេតការណ៍នូវរាល់សកម្មភាពនានារបស់ក្រុមប្រឹក្សា/ស្មៀនឃុំ សង្កាត់ គណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលបោះឆ្នោត ។

៦. ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លទ្ធផលផ្លូវការជាមួយនឹងលទ្ធផលបណ្តោះអាសន្ន ដែលបានកត់ត្រាក្នុងអំឡុងពេលនៃការរាប់សន្លឹកឆ្នោតនៅថ្ងៃរាប់សន្លឹកឆ្នោត ។

៧. ធ្វើរបាយការណ៍អំពីការរំលោភច្បាប់ ឬបទបញ្ជា និងនីតិវិធីដែលត្រូវបានចោទប្រកាន់ និងអំពីភាពមិនប្រក្រតីនានាជូនថ្នាក់ដឹកនាំផ្ទាល់របស់ខ្លួន និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ ។

៨. រក្សាការសម្ងាត់នៃការបោះឆ្នោត ។

៩. មានសេរីភាពធ្វើរបាយការណ៍ស្តីពីការរកឃើញ ការកត់សម្គាល់ និងសេចក្តីសន្និដ្ឋានរបស់ខ្លួន ឆ្លងតាមរយៈថ្នាក់ដឹកនាំរបស់ខ្លួន ដោយផ្អែកតាមការណែនាំជាកំណត់របស់ថ្នាក់ដឹកនាំ ឬអង្គការរបស់ខ្លួន ។

១០. មានសេរីភាពក្នុងការជួប ឬនិយាយជាមួយគ្រប់បេក្ខជន ឬគណបក្សនយោបាយ និងមន្ត្រីបោះឆ្នោត ប្រសិនបើកម្មវត្ថុនៃការជជែកនោះ មិនទាក់ទងនឹងការគាំទ្រ ឬប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១១. ត្រូវគោរពច្បាប់ដែលមានជាធរមាននៅកម្ពុជា និងត្រូវទទួលស្គាល់អធិបតេយ្យភាពនៃព្រះរាជាណាចក្រកម្ពុជា ។

១២. ត្រូវតែយល់ដឹងពីច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោត ។ ក្នុងករណីមានការរំលោភត្រូវធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដោយផ្អែកលើមូលដ្ឋានឯកសារត្រឹមត្រូវព្រមទាំងភ័ស្តុតាងច្បាស់លាស់ និងអាចពន្យល់បញ្ជាក់បាន ។





១៣. មានសិទ្ធិចេញចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

១៤. ចំនួនអ្នកសង្កេតការណ៍ ដែលចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតក្នុងពេលតែមួយ ត្រូវបានកំណត់ត្រឹម ៤(បួន)នាក់ យ៉ាងច្រើន។ ក្នុងករណីមានអ្នកសង្កេតការណ៍ច្រើនលើសពី ៤(បួន)នាក់ អ្នកសង្កេតការណ៍ទាំងនោះ ត្រូវធ្វើការផ្លាស់ប្តូរតាមការកំណត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ/និងប្រធានការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត។

១៥. ត្រូវមានជំហរអព្យាក្រឹត និងមិនត្រូវប្រកាន់បក្សពួក ហើយត្រូវជៀសវាងក្នុងការបង្ហាញឱ្យគេ ឃើញតាមរយៈឯកសណ្ឋានពណ៌ ឬវត្ថុដទៃទៀតដែលជានិមិត្តរូបនៃការគាំទ្រ ឬការប្រឆាំងនឹងបេក្ខជន ឬគណបក្សនយោបាយណាមួយ ។

១៦. ត្រូវបង្ហាញភ័ស្តុតាងបញ្ជាក់អំពីអត្តសញ្ញាណរបស់ខ្លួនភ្លាមដល់

អាជ្ញាធរមានសមត្ថកិច្ច ដែលបានសាកសួរដល់ខ្លួន ហើយត្រូវពាក់ប័ណ្ណសម្គាល់ខ្លួន ដែលបានសម្រេចទទួលស្គាល់ និងចេញឱ្យដោយលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

១៧. ពុំមានសិទ្ធិចូលរួមជជែកវែកញែក ក្នុងដំណើរការដោះស្រាយបណ្តឹងណាមួយក្នុងអំឡុងពេលបោះឆ្នោតឡើយ ប៉ុន្តែអាចសង្កេតការណ៍លើការដោះស្រាយបណ្តឹងនេះបាន ។

១៨. ក្នុងអំឡុងពេលចុះសង្កេតការណ៍នៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត រាប់សន្លឹកឆ្នោតណាមួយ ត្រូវប្រតិបត្តិតាមគោលការណ៍ណែនាំ និង នីតិវិធី ដែលបានកំណត់ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការណែនាំរបស់មន្ត្រីបោះឆ្នោត ឬគណៈកម្មការបោះឆ្នោតនៅថ្នាក់ក្រោម ហើយមិនត្រូវធ្វើឱ្យរាំងស្ទះដល់ដំណើរនៃការបោះឆ្នោតឡើយ ។





១៩. ត្រូវទទួលខុសត្រូវទូទាត់ផ្ទាល់ដោយខ្លួនឯង ឬ/និងដោយអង្គការរបស់ខ្លួនលើរាល់តម្លៃ និងការចំណាយផ្សេងៗទៀតនៅក្នុងអំឡុងពេលនៃបេសកកម្មសង្កេតការណ៍របស់ខ្លួន ។

## ខ. បម្រាមសម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត

ក្នុងការសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយសម្រាប់ឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត និងរាល់សកម្មភាពនានា នៅការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទាំងនៅមុនពេល ក្នុងពេល និងក្រោយពេលនៃការបោះឆ្នោត អ្នកសង្កេតការណ៍ ត្រូវជៀសវាង ៖

១. ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងកម្ពុជា ។

២. ការជជែកពិភាក្សាទាក់ទងនឹងបញ្ហាគាំទ្រ ឬប្រឆាំងគណបក្សនយោបាយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោតណាមួយ ជាមួយនឹងអ្នកចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោតណាម្នាក់ឡើយ ។

៣. ការត្រួវរំខាន ឬការជ្រៀតជ្រែកក្នុងកិច្ចការផ្សេងៗរបស់

គណៈកម្មការរៀបចំការបោះឆ្នោតនៅថ្នាក់ណាមួយឡើយ នៅពេលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ការបោះឆ្នោត និងរាប់សន្លឹកឆ្នោតកំពុងប្រព្រឹត្តទៅ។

៤. ការយកតាមខ្លួននូវគ្រឿងអាវុធ ជាតិផ្ទុះ ឬវត្ថុដែលអាចបង្កឱ្យមានគ្រោះថ្នាក់ក្នុងអំឡុងពេលបំពេញភារកិច្ចសង្កេតការណ៍របស់ខ្លួនឡើយ ។

៥. មានសិទ្ធិសាកសួរ និងលើកសំណួរចំពោះមន្ត្រីរៀបចំការបោះឆ្នោត ប៉ុន្តែមិនត្រូវផ្តល់ដំបូន្មាន ឬស្តីបន្ទោសកែតម្រូវកំហុសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ដែលខ្លួនបានរកឃើញ និងបង្អាក់ដំណើរការបោះឆ្នោតឡើយ ។ អាចធ្វើរបាយការណ៍អំពីបញ្ហាធ្ងន់ធ្ងរជាបន្ទាន់ជូនគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ និងត្រូវជូនរបាយការណ៍នេះ មួយច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផង ។





៦. ការប៉ះពាល់ឯកសារ ឬសម្ភារៈ បរិក្ខារបោះឆ្នោត ក្នុងនោះរួមទាំងសន្លឹកឆ្នោតផង ។

៧. ការប្រើប្រាស់ម៉ាស៊ីនថតរូប ថតវីដេអូ ថតសំឡេង ឬទូរស័ព្ទថតរូបនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត ។

៨. ការនៅក្បែរបន្ទប់សម្ងាត់សម្រាប់គូសសន្លឹកឆ្នោតឡើយ ។

## VI. ទោសប្បញ្ញត្តិ

ដោយមិនទាន់គិតពីទោសប្បញ្ញត្តិដូចមានចែងក្នុង ច.ប.ឃ.ស គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានអំណាចឆន្ទានុសិទ្ធិក្នុងការបដិសេធលែងទទួលស្គាល់អង្គការសង្កេតការណ៍ ឬអ្នកសង្កេតការណ៍ណាមួយ នៅពេលដែលគណៈកម្មការនោះ យល់ឃើញថា អង្គការ ឬអ្នកសង្កេតការណ៍នោះ ៖

ក. មិនគោរពតាមសេចក្តីណែនាំ និងសេចក្តីបង្គាប់បញ្ជារបស់មន្ត្រីបោះឆ្នោតមានសមត្ថកិច្ចថ្នាក់ណាមួយ ។

ខ. បង្ហាញជាសាធារណៈថា បានលំអៀងទៅលើបេក្ខជន

ឬគណបក្សនយោបាយណាមួយ ។

គ. បង្អាក់ ឬធ្វើឱ្យរាំងស្ទះក្នុងការបំពេញការងារនៃមន្ត្រីបោះឆ្នោត ។

ឃ. រំលោភបំពានលើក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍បោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រគល់សិទ្ធិជូនគណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ឱ្យបណ្តេញចេញពីទីស្នាក់ការ ឬការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនូវអ្នកសង្កេតការណ៍ទាំងឡាយណាដែលពុំបានគោរពតាមក្រមសីលធម៌នេះ ។ ដើម្បីអនុវត្តសិទ្ធិអំណាចខាងលើ គណៈកម្មការរៀបចំការបោះឆ្នោតថ្នាក់ក្រោម ត្រូវរាយការណ៍ពីព្រឹត្តិការណ៍នេះ តាមឋានានុក្រមមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## VII. នីតិវិធីនទទួលស្គាល់អ្នកសង្កេតការណ៍

### ក. អ្នកសង្កេតការណ៍ជាតិ

១. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យពាក្យ





សុំ និងសម្រេចទទួលស្គាល់អ្នកសង្កេតការណ៍ជាតិ ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រគល់សិទ្ធិអំណាចឱ្យមន្ត្រីនៃលេខាធិការដ្ឋានខេត្ត ក្រុងរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្ត ក្រុងរៀបចំការបោះឆ្នោតពាក់ព័ន្ធចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍ជាតិ និងប័ណ្ណសម្គាល់ខ្លួនភ្នាក់ងារគណបក្សនយោបាយដែលមិនមានបេក្ខជនឈរឈ្មោះបោះឆ្នោត ។ ប័ណ្ណសម្គាល់ខ្លួននេះនឹងអនុញ្ញាត ឱ្យអ្នកសង្កេតការណ៍ជាតិមានសិទ្ធិ និងបំពេញភារកិច្ចរបស់ខ្លួននៅការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅខេត្ត ក្រុង ។ ប័ណ្ណសម្គាល់ខ្លួននេះ ត្រូវតែជាប័ណ្ណដែលផលិតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

៣. ប័ណ្ណសម្គាល់ខ្លួននេះ ក៏អាចប្រើប្រាស់បាននៅក្នុងការបោះ

ឆ្នោតសាជាថ្មីណាមួយ ដែលអាចធ្វើឡើង បន្ទាប់ពីមានការបដិសេធលទ្ធផលបោះឆ្នោតនៃការិយាល័យបោះឆ្នោតណាមួយនោះ ។

**៩. អ្នកសង្កេតការណ៍អន្តរជាតិ**

១. អ្នកសង្កេតការណ៍អន្តរជាតិ ឬអង្គការអន្តរជាតិណាមួយដែលចង់ចូលរួមសង្កេតមើលការបោះឆ្នោតនៅព្រះរាជាណាចក្រកម្ពុជា អាចទាក់ទងជាមួយស្ថានឯកអគ្គរាជទូតកម្ពុជា ដែលប្រចាំនៅសាមីប្រទេស ។

២. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យ សម្រេច និងចេញប័ណ្ណសម្គាល់ខ្លួនឱ្យអ្នកសង្កេតការណ៍អន្តរជាតិ ។ អ្នកសង្កេតការណ៍អន្តរជាតិត្រូវបានអនុញ្ញាតឱ្យសង្កេតការណ៍នៅតាមការិយាល័យចុះឈ្មោះបោះឆ្នោត ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## VIII. សំណូមពរ

បន្ទាប់ពីដំណើរបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់



គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

អាណត្តិទី ២ ឆ្នាំ ២០០៧ បានចប់សព្វគ្រប់ហើយ សាមីអង្គការសង្កេតការណ៍ទាំងឡាយត្រូវផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរស្តីពីការសង្កេតឃើញ និងសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងដំណើរការនៃការបោះឆ្នោតផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានមូលដ្ឋានគ្រឹះសម្រាប់ធ្វើការវាយតម្លៃជាចុងក្រោយ ។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ភ្នំពេញ ថ្ងៃទី២៨ ខែ កញ្ញា ឆ្នាំ២០០៦

**ប្រតិទិននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៧**

| ការកិច្ចត្រូវបំពេញ | កាលបរិច្ឆេទ |
|---|---|
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត និងការិយាល័យចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតចុងក្រោយ ( *បញ្ជីបោះឆ្នោតឆ្នាំ២០០៥* ) | ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០៦ |
| ការចាប់ផ្ដើមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ១ ខែតុលា ឆ្នាំ២០០៦ |
| ការបញ្ចប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត | ថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីដំបូង តាមករណីគ្មានបណ្ដឹង ឬដោះស្រាយបណ្ដឹងរួចរាល់ | ថ្ងៃទី២៤ ខែតុលា ដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ |
| ការផ្ដល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ |
| ការបិទផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោតនៅ គឃ/សប | ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ |
| ការទទួលពាក្យសុំចុះបញ្ជីបេក្ខជនរបស់គណបក្សនយោបាយ រយៈពេល៣ថ្ងៃ ដោយ គឃ/សប | ថ្ងៃទី១-៣ ខែមករា ឆ្នាំ២០០៧ |
| ការសម្រេចរបស់ គឃ/សប លើពាក្យសុំចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបេក្ខជនដំបូងនៅ គឃ/សប | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបេក្ខជនផ្លូវការ នៅ គឃ/សប | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ |
| ការឃោសនាបោះឆ្នោត | ថ្ងៃទី១៦-៣០ ខែមីនា ឆ្នាំ២០០៧ |
| ការបិទផ្សាយបញ្ជីបោះឆ្នោតនៅការិយាល័យបោះឆ្នោត | ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៧ |
| ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងបិទផ្សាយលទ្ធផលនៅការិយាល័យបោះឆ្នោត | ថ្ងៃទី១ ខែមេសា ឆ្នាំ២០០៧ |
| ការត្រួតពិនិត្យ បូកសរុប និងបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៅ គឃ/សប រយៈពេល៣ថ្ងៃ | ថ្ងៃទី២-៤ ខែមេសា ឆ្នាំ២០០៧ |
| ការប្ដឹងជំទាស់ពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនៅតាមឃុំ សង្កាត់ទៅ គខ/កប រយៈពេលយ៉ាងយូរ៣ថ្ងៃ បន្ទាប់ពីបិទផ្សាយនៅតាមឃុំ សង្កាត់នោះ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០០៧ |
| ការសម្រេចលើបណ្ដឹងជំទាស់ដោយ គខ/កប រយៈពេល៥ថ្ងៃ បន្ទាប់ពីទទួលពាក្យបណ្ដឹង | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ |
| ការប្ដឹងតវ៉ាលើសេចក្ដីសម្រេចរបស់ គខ/កប ទៅ គ.ជ.ប រយៈពេល៤ថ្ងៃ បន្ទាប់ពីទទួលទំរង់បែបបទបដិសេធ | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៧ |
| ការសម្រេចលើបណ្ដឹងតវ៉ាដោយ គ.ជ.ប រយៈពេល៤ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ |
| ការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោត | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៧ |
| ការបោះឆ្នោតសាជាថ្មី | កាលបរិច្ឆេទចុងក្រោយ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៧ |